ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# រដ្ឋាភិបាលចិនប្រកាន់ជំហរឥតងាករេ គោរពឯករាជ្យ អធិបតេយ្យ ការការពារសន្តិសុខ និងស្ថេរភាពសង្គមនៅកម្ពុជា

*********

ឯកឧត្តម Liu Shaobin អគ្គនាយកនៃអគ្គនាយកដ្ឋានសន្តិសុខក្រៅប្រទេសនៃក្រសួងការបរទេសចិន បានអះអាងជូន ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អំពីជំហរឥតងាករេរបស់រដ្ឋាភិបាលចិន ក្នុងការគោរពឯករាជ្យ អធិបតេយ្យ និងការចាត់វិធានការនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការការពារសន្តិសុខ និងស្ថេរភាពសង្គម។ ការអះអាងនេះ ត្រូវបានធ្វើឡើងក្នុងឱកាសចូលជួបសម្តែងការគួរសមជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** នៅព្រឹកថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៨ ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំពិគ្រោះយោបល់កម្ពុជា-ចិន លើកទី៣ ស្តីពីបញ្ហាសន្តិសុខគ្រប់ជ្រុងជ្រោយ និងកិច្ចប្រជុំក្រុមការងារការពារសន្តិសុខនៃការអនុវត្តគំរោងខ្សែក្រវ៉ាត់និងផ្លូវ នៅខេត្តសៀមរាប ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨។

ឯកឧត្តមអគ្គនាយក Liu Shaobin បានជម្រាបឯកឧត្តមទេសរដ្ឋមន្ត្រី ពីជំហររបស់រដ្ឋាភិបាលចិនយកចិត្តទុកដាក់ពង្រឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ ជាពិសេសនៅក្នុងឆ្នាំ២០១៨នេះ ដែលជាខួបលើកទី៦០ នៃទំនាក់ទំនងការទូតកម្ពុជា-ចិន។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងអំណរគុណ និងវាយតំលៃខ្ពស់ចំពោះជំហរខាងលើនេះរបស់រដ្ឋាភិបាលចិន។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានធ្វើការកត់សម្គាល់ដោយពេញចិត្តចំពោះការវិវត្តដ៏ល្អក្នុងទំនាក់ទំនងទ្វេភាគី និងការផ្លាស់ប្តូរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ ដែលបានរួមចំណែកដ៏សំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រង់ជ្រោយ ពិសេសទស្សនកិច្ចផ្លូវការនៅកម្ពុជារបស់ឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីចិន ក្នុងខែមករា ឆ្នាំ២០១៨ ដែលក្នុងឱកាសនោះ ភាគីទាំងពីរបានចុះហត្ថលេខាលើឯកសារចំនួន១៩ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើន។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានជំរាបជូនគណៈប្រតិភូ អំពីគំរោងទស្សនកិច្ចរបស់ឯកឧត្តមផ្ទាល់ទៅប្រទេសចិន ក្នុងអនាគតខាងមុខ ដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ហើយក៏បានវាយតំលៃខ្ពស់ចំពោះការកើនឡើងនូវទុនវិនិយោគរបស់ចិន ដែលជាការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ឯកឧត្តមទេសរដ្ឋមន្ត្រី និងឯកឧត្តមអគ្គនាយក ក៏បានពិភាក្សាគ្នាអំពីភាពចាំបាច់នៃការបង្កើនកិច្ចសហប្រតិបត្តិការការពារសន្តិសុខ និងការប្រឆាំងភេរវកម្ម ផងដែរ។

នៅក្នុងជំនួបនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រីបានជំរាបជូនគណៈប្រតិភូអំពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ ក្នុងការត្រៀមរៀបចំការបោះឆ្នោតទូទៅនាខែកក្កដាខាងមុខ ឲ្យប្រព្រឹត្ត

ទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានលក្ខណៈប្រជាធិបតេយ្យ ហើយបានគូសបញ្ជាក់អំពីការចូលរួមប្រកួតប្រជែងរបស់គណបក្សនយោបាយជាច្រើន ក្នុងចំណោមនោះក៏មានគណបក្សដែលមាននិន្នាការប្រឆាំងមួយចំនួនផងដែរ។ ឯកឧត្តមអគ្គនាយក Liu Shaobin បានជម្រាបឯកឧត្តមទេសរដ្ឋមន្ត្រី អំពីជំហររបស់ចិនគាំទ្រយ៉ាងពេញលេញចំពោះការបោះឆ្នោតទូទៅនៅកម្ពុជានាខែកក្កដាខាងមុខនេះ។

ជំនួបបានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃ ចន្ទ ៨រោច ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៨